# កិច្ចសំភាសន៍របស់អ៊ុំប្រុសឈ្មោះ ឡៃ្យង ពៅ

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី          ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ ឡៃ្យង ពៅ

កៈ អ៊ុំជាដំបូងសូមជំរាបសួរអ៊ុំ!

ខៈ បាទជំរាបសួរ!

កៈ ចាសអ៊ុំ! អឺ...ថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងមកធ្វើការសំភាសន៍របស់អ៊ុំផ្ទាល់ហើយអឺ...អ៊ុំខ្ញុំធ្វើការស្ម័គ្រចិត្តរបស់ខាងគំរោងនៅខាងសាលា BYU នៅខាងសហរដ្ឋអាមេរិចណាស់អ៊ុំ?

ខៈ បាទ!

កៈ ហើយគំរោងរបស់សាលាមួយនឹងគេចង់ជួយចងក្រងរបស់ពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើងទៅពីជីវិតបទពិសោធន៍របស់គាត់តាំងពីមុនរហូតមកដល់តល្វូវថាគាត់ធ្លាប់បានជួបនឹងបញ្ហាអីគេខ្លះ! ដើម្បីគេចាត់ចែងនឹងអឺ...ធ្វើការចងក្រងជាឯកសារដើម្បីអោយកូនចៅជំនាន់ក្រោយគេបានស្តាប់ដែរអញ្ចឹងណាស់អ៊ុំ?

ខៈ ប្រជាជនណា?

កៈ ចាស?

ខៈ ប្រជាជនណា?

កៈ ប្រជាជនកម្ពុជា ដូចថាប្រជាជនដែលគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើងទៅដូចជាអ៊ុំមួយនឹងមិនជាប្រជាជនមួយរូបនៅក្នុងប្រទេសកម្ពុជា!

ខៈ បាទ!

ក៖ ចាស! អញ្ចឹងអ៊ុំអឺ...មានជីវប្រវត្តិបែបណាអញ្ចឹងនឹងគឺគេចង់ជួយចងក្រងវាទុកកុំអោយបាត់បង់ណាស់ឧទាហរណ៍ថាផុតពីជំនាន់របស់អ៊ុំអញ្ចឹងទៅ...

ខ៖ បាទ!

ក៖ មានកូនចៅជំនាន់ក្រោយគេអាចស្តាប់បាន! ចាស អញ្ចឹងថ្ងៃនេះខ្ញុំមានឪកាសដើម្បីនឹងធ្វើការសំភាសនស៍អ៊ុំ...

ខ៖ បាទ!

ក៖ តើអ៊ុំអនុញ្ញាតអោយខ្ញុំធ្វើការសំភាសន៍អ៊ុំថតរូបរបស់លោកអ៊ុំនឹងយកសំលេងរបស់លោកអ៊ុំយកទៅ Post នៅក្នុងវេបសាយដែរឬទេលោកអ៊ុំ?

ខ៖ បាទ! ខ្ញុំមិនសូវជាចេះដែរទេ បើគាត់បានចេះ!

ក៖ នឹងហើយ! តែអឺ...ការសំភាសន៍មួយនឹងវាអត់មានត្រូវការចេះអីទេប៉ុន្តែគ្រាន់តែថាប្រវត្តិជីវិតរបស់មនុស្សម្នាក់ៗមានការខុសៗគ្នាអញ្ចឹងណាស់អ៊ុំ?

ខ៖ បាទ!

ក៖ ហើយគេចង់ជួយចងក្រងពង្សប្រវត្តិរបស់អ៊ុំណាស់អញ្ចឹងអ៊ុំមានខ្សែជីវិតបែបណាវាផ្សេងពីជីវិតរបស់លោក...អ៊ុំ លោកតាមិញណាស់ ចាស!

ខ៖ ខ្ញុំកាលពីខ្ញុំនៅពីអាយុ ១៦ឆ្នាំនឹងខ្ញុំនៅ...នៅរៀន!

ក៖ ចាសនឹងហើយ!

ខ៖ ខ្ញុំរៀនបានថ្នាក់ទីប្រាំពីរ!

ក៖ ចាស!

ខ៖ ហើយពីជំនាន់ព្រះសីហានុណាស់!

ក៖ ចាស!

ខ៖ បាទ! ដល់ពេលនឹងអឺ...ទៅពីជំនាន់ព្រះសីហានុនឹងទៅអាពតជំលៀសទៅក៏ខ្ញុំនៅនឹងខេត្តព្រៃវែង!

ក៖ ចាស!

ខ៖ ស្រុកកញ្ច្រៀច ខេត្តព្រៃវែង ឃុំនាងរាជ!

ក៖ អូ...

ខ៖ បាទ (ក្រហែម) ដល់...

ក៖ នឹងជាស្រុកកំណើតរបស់អ៊ុំហ៎?

ខ៖ ស្រុកកំណើតខ្ញុំនៅនឹង!

ក៖ ចាស!

ខ៖ ដល់ឪពុកម្ដាយរបស់ខ្ញុំគាត់ស្លាប់អស់ហើយ!

ក៖ ចាសអ៊ុំ!

ខ៖ បាទ! ដល់...

ក៖ ចុះអ៊ុំមានឈ្មោះអីដែរ?

ខ៖ ឡេង ឈ្មោះ ទូច ឡេង!

ក៖ លោកអ៊ុំ ទូ ឡេង?

ខ៖ ទូច ឡេង ទូច...ទូច!

ក៖ ទូច ហ៎លោកអ៊ុំ?

ខ៖ បាទៗ!

កៈ ចាសហើយ...

ខៈ ម្ដាយរបស់ខ្ញុំឈ្មោះ លីម គីមហុង!

កៈ ចាស!

ខៈ ហើយអឺ...ខ្ញុំត្រូវជាក្មួយរបស់លោកតាធំលោកយាយធំម៉ង!

កៈ ចាស!

ខៈ សម្ដេចហើយសម្ដេចនឹងត្រូវជាមារបស់ខ្ញុំ!

កៈ ចាស!

ខៈ ហើយទៅគាត់សុគតបាត់ហើយ!

កៈ អូ...

ខៈ ហើយបន្ទាប់មកបានអ៊ុំនីមនឹង ម៉ែនីមនឹងគាត់បានឡើងទៅជាអនុ!

កៈ ចាស!

ខៈ ហើយគាត់នឹងពីរនាក់នឹងត្រូវនៅតំណាលដែរ!

កៈ ចាស!

ខៈ អូ...ខ្សែជីវិតរបស់ខ្ញុំនឹងច្រើនណាស់!

កៈ អូ...ចាសត្រូវហើយ ចាស! អ៊ុំអាយុប៉ុន្មានហើយ?

ខៈ ខ្ញុំឯណោះបានជីវិតគាត់ ខ្ញុំណាស់!

កៈ ចាស!

ខៈ បាទ!

កៈ អ៊ុំអាយុប៉ុន្មានហើយឆ្នាំនឹង?

ខ៖ ខ្ញុំ៦០ គត់!

ក៖ ៦០ គត់ហើយន៏អ៊ុំឆ្នាំនឹង?

ខ៖ បាទ!

ក៖ ចាស! អ៊ុំកើតនៅក្នុងឆ្នាំណាដែរ?

ខ៖ ខ្ញុំកើត ១៩៥៩!

ក៖ ១៩៥៩?

ខ៖ បាទ!

ក៖ អូ...ហើយអ៊ុំកើតនៅក្នុងថ្ងៃខែណាដែរអ៊ុំចាំដែរឬទេ?

ខ៖ ខ្ញុំអត់ដឹងថ្ងៃកើតផង!

ក៖ ចុះឆ្នាំខ្មែរហើយឆ្នាំចន្ទគតិណាស់!

ខ៖ បាទ!

ក៖ ដូចឆ្នាំសត្វអីនឹងអ៊ុំចាំដែរឬទេ?

ខ៖ ខ្ញុំ...ខ្ញុំ...

ក៖ ជូត ឆ្លូវ ខាល ថោះ អីណាស់?

ខ៖ ខ្ញុំឆ្នាំកោរ បាទ!

ក៖ ឆ្នាំ កោរ!

ខ៖ កោរ កុរ ណាស់!

ក៖ ចាស! ចាស...

ខ៖ ខ្ញុំកើតនៅឆ្នាំ ១៩៥៩!

កៈ ចាសអុំ!

ខៈ ហើយកាលនឹងជំនាន់អាពតចូលនឹងនៅឆ្នាំ ១៩៧៥!

កៈ ចាសអុំ!

ខៈ កាលនឹងខ្ញុំគេជំលៀសចេញទៅដល់ពេល៧៩ (ឆ្នាំ១៩៧៩) អង្គការរបស់យើងនឹងគេរំដោះ!

កៈ ចាស!

ខៈ ហើយនឹងម្ដាយរបស់ខ្ញុំនឹងក៏ខ្ញុំចេញមកដើរមកឪពុកម្ដាយរបស់ខ្ញុំនឹងគាត់នៅទេ!

កៈ ចាស!

ខៈ តែឪពុករបស់ស្លាប់នៅតែម្ដាយវេទនាណាស់!

កៈ អ៊ឹម!

ខៈ ម្ដាយរបស់ខ្ញុំនៅតាំងគោកឯណោះ កំពង់ធំឯណោះ!

កៈ អ៊ឹម...

ខៈ ដឹងម៉េចបានជួបគ្នា បានតាតានឹងយាយយាយនឹងបានគាត់ជួបគ្នាខ្ញុំឆ្ងល់ដែរ!

កៈ អ៊ឹម!

ខៈ បាទ! អានឹងមកពីប្រវត្តិរបស់ពួកគាត់តស៊ូ!

កៈ នឹងហើយ!

កៈ ចាស!

ខៈ (ក្រហែម) កាលនឹងគាត់ខំរកណាស់ខំចិញ្ចឹមកូនអោយរៀនសូត្រចេះដឹងដើម្បីកុំអោយកូនល្ងង់!

កៈ ចាស!

ខ៖ ដើម្បីតែលូង់គេអូសទាញហើយ!

ក៖ នឹងហើយអ៊ុំ!

ខ៖ អូសទាញទៅ ទៅនៅនឹងយើងមិនវក់ល្បែង មិនបំភ្លេចឪពុកម្ដាយ!

ក៖ ចាសអ៊ុំ!

ខ៖ ទីមួយគឺគាត់ខិតខំរកស៊ីចិញ្ចឹមយើង... (សំលេងរបស់លោកអ៊ុំយំ)!

ក៖ អូ...អ៊ុំសូមទោសណាស់ដែលបានលឺអញ្ចឹងណាស់អ៊ុំ ប៉ុន្តែអឺ...ដោយសារតែជីវិរបស់ប្រជាជនកម្ពុជាធ្លាប់មាននូវបញ្ហាលំបាកច្រើនមិនមែនតែអ៊ុំម្នាក់នោះទេ មានគេច្រើនណាស់ដែលកើតមានបញ្ហានឹងអញ្ចឹងណាស់!

ខ៖ និយាយអត់រួចទេ!

ក៖ អ៊ឹម...ហើយអឺ...អ៊ុំអត់អីទេតាមសំរួលទៅអ៊ុំកាត់ចិត្តទៅណាស់អ៊ុំព្រោះកាលពីមុននឹងវាអញ្ចឹងហើយអ្នកណាគេក៏គេធ្លាប់ជួបដែរកាលពីមុននឹងយាយរបស់ខ្ញុំម៉ាក់របស់ខ្ញុំអីកាលនឹងគាត់ប្រាប់ជីវិតរបស់គាត់នឹងក៏កំសត់ៗច្រើនណាស់ជួបបញ្ហាអីច្រើនគគោក តែដល់ពេលក្រោយមកនឹងគាត់ខំតស៊ូណាស់អ៊ុំជំនះវាអញ្ចឹងឯងទៅបានគាត់អឺ...ខំប្រឹងឥលូវរៀងគ្រាន់បើជាងមុនចាស (លោកអ៊ុំក្រហែម) ប៉ុន្តែខ្ញុំកើតអត់ទាន់ទេខ្ញុំសរសើរពួកគាត់មែនទែនដែលខំប្រឹងមកណាស់!

ខ៖ បាទ!

ក៖ ចាស! ដល់ពេលក្រោយមក...

ខ៖ ខ្ញុំនឹងក៏ខំប្រឹងដើរមកនេះ កាលនឹងអត់មានអ្នកចិញ្ចឹមទេ!

ក៖ អូ...ជើងរបស់អ៊ុំនឹងកើតប៉ុន្មានឆ្នាំហើយ?

ខ៖ អឺ...មួយឆ្នាំ ពីរឆ្នាំហើយ អត់ទេពីមុនខ្ញុំដើររួច!

ក៖ នឹងហើយ!

ខ៖ ដល់ពេទ្យកាលនៅតូចៗពេទ្យមកចាក់ថ្នាំខ្ញុំ ពេលចាក់សរសៃរចាក់ចំសរសៃរទៅក៏អញ្ចឹងម៉ង!

ក៖ អូ...កាលនឹងអ៊ុំកើតអីបានគេចាក់?

ខ៖ ខ្ញុំគ្រុន!

ក៖ គ្រុនក្តៅហ៎?

ខ៖ បាទ! លោកពូនឹងគាត់យកខ្ញុំទៅពេទ្យដល់បោះបង់ទៅមាននេះគាត់ធ្វើអាចារ្យ មានតែ...មានតែពីរម្តាយគត់!

ក៖ អឺម!

ខ៖ បានមិនដឹងបាយឯណាអីមិនដឹងឯណាគេចែកអោយម្នាក់បន្តិចៗនឹងចេះតែហូបទៅ ដល់តែវាចេះតែពេល...ពេលពូខ្ញុំទំនេរអញ្ចឹងនឹងយកបាយទៅយកបន្តិចទៅ!

ក៖ ចាស!

ខ៖ អឺម! ជីវិតរបស់ខ្ញុំនឹងក្រណាស់ ហើយកូនខ្ញុំគេមាន...

ក៖ នឹងហើយបែកពីអាពតនឹងមកដូចតែគ្នានឹងអ៊ុំក្រដូចតែគ្នានឹង!

ខ៖ បាទ! កូនរបស់ខ្ញុំមានបាទ កូនខ្ញុំមាន!

ក៖ អូ...

ខ៖ ពូមុននឹងនៅប៉ោយប៉ែតឯណោះ!

ក៖ ចាស!

ខ៖ វាមកម៉េចនឹងកើត ពីមុននឹងនៅនឹងផ្សារដីហុយ!

ក៖ ចាស!

ខ៖ បើខ្ញុំទៅលេងបានតែ ខ្ញុំនិយាយប្រាប់អូនឯងតាមត្រង់ចុះ បើខាង...បើខាងប្តីរបស់វាទៅបានទៅដល់កំពតនាំកូនទៅលេង!

ក៖ អឺម!

ខ៖ ចំណែកខ្ញុំនៅនឹងបន្ទប់បរពិត បំបាច់ខ្ញុំឈឺណាស់ឪពុករបស់ខ្ញុំតែទៅវាណាស់អត់មកមើលឪពុកបន្តិចទេ តែខ្ញុំស្រលាញ់ចៅ!

ក៖ ចាស!

ខ៖ ចៅក្រមុំអស់ហើយនៅរៀន!

ក៖ (សើច) អញ្ចឹងហ៎?

ខ៖ មួយថ្នាក់ទីប្រាំបួន មួយទៀតថ្នាក់ទីប្រាំបី!

ក៖ ចាស!

ខ៖ អោយតែឃើញខ្ញុំសំពះសួរខ្ញុំដល់ហើយខ្ញុំវាចិត្តវាមិនដាច់ ដល់តែបានលុយបន្តិចបន្តួចទៅអោយចៅទៅបាទ ហើយទៅអាប្តីនឹងគិតតែលេងបៀរ ខ្ញុំថាខ្សែជីវិតរបស់កូនឯងដឹងហើយអានឹងហើយមើលងាយឪពុកម្តាយដល់តែពេលបានប្តីៗធ្វើបាបផ្ទះលក់ផ្ទះអស់រលីង!

ក៖ អឺម!

ខ៖ ផ្ទះនៅនឹងផ្សារដីហុយនឹងលក់អស់មួយ!

ក៖ អឺម!

ខ៖ ហើយវាប្តីរបស់វានឹងមានស្រីទៀត ដល់តែពេលប្តីមានស្រីទៅយកប្តីមួយទៀតខ្ញុំពិតនាងខ្ញុំនិយាយនៅនឹងមុខព្រះអង្គ ដល់តែប្តីមានស្រីមកវិញកូនរបស់ខ្ញុំនឹងយកវាទៀត!

ក៖ អ៊ុំមានកូនទាំងអស់ប៉ុន្មាននាក់?

ខ៖ កូនរបស់ខ្ញុំពីរគត់!

ក៖ ស្រីទាំងពីរហ៎អ៊ុំ?

ខ៖ បាទ!

ក៖ អូ...

ខ៖ ហើយមីមួយនឹងប៉ោយប៉ែតនឹងមិនដែលមកទេ!

ក៖ ប្រពន្ធរបស់អ៊ុំមានឈ្មោះអីដែរ?

ខ៖ ប្រពន្ធរបស់កាលនេះនឹងគាត់ស្លាប់បាត់ហើយ!

ក៖ គាត់ស្លាប់យូរហើយន៍អ៊ុំ?

ខ៖ បាទ! ស្លាប់បីបួនឆ្នាំហើយ!

ក៖ អូ...គាត់កើតអីគេកាលនឹងអ៊ុំ?

ខ៖ អត់ផង គាត់...និយាយត្រង់ចុះប្រពន្ធរបស់ខ្ញុំផឹកប្រមឹក វាអញ្ចេកបើវាតាមគេតាមឯងនឹងដើរលេងបៀរវា!

ក៖ អ៊ឹម!

ខ៖ និយាយត្រងម៉ងនៅនឹងមុខប្អូនឯងខ្ញុំនិយាយត្រង់ម៉ង ខ្ញុំអត់ចេះលាក់ទេខ្ញុំចេះតែនិយាយត្រង់ម៉ងដល់ពេលលេងបៀរខ្សោយទាំងយប់ទាំងថ្ងៃៗ....

ក៖ អ៊ឹម!

ខ៖ ខ្ញុំនិយាយអត់ស្ដាប់ ហើយកូនប្រសាររបស់ខ្ញុំលែងចង់មើលមុខហើយខ្ញុំថាឥលូវបើឯងលេងបៀរដាច់គ្នាម៉ងទៅ!

ក៖ អ៊ឹម!

ខ៖ ដាច់គ្នារហូត ដាច់គ្នាបីឆ្នាំហើយដល់ហើយកូនគេមកថាប៉ា ម៉ែស្លាប់ហើយ ហ្អាក់?? ដល់នេះទៅខ្ញុំទៅធ្វើបុណ្យអីនឹងហៅខ្ញុំទៅមានអីកូនប្រសារខ្ញុំមានវាអាណិតខ្ញុំដែរនឹងកូនប្រសាររបស់ខ្ញុំនឹងពីរ បើអានៅនឹងប៉ោយប៉ែតនឹងអឹម...អានោះគ្រាន់បើជាងប្តីវាទៀត!

ក៖ អឹម...អញ្ចឹង?

ខ៖ ខ្ញុំមកនឹងថាប្អូនរបស់វា...បងរបស់វាលក់ម៉ូតូម៉េចក៏វាមិនមានមាត់ដែរ!

ក៖ អឹម!

ខ៖ ហៅវាមកថាកូនឯង មីប្អូនអត់ចេះទេអត់ចេះលួចអត់ចេះអីទេ ហើយហែងនឹងខ្លាចប្តីហែងម្លេះ!

ក៖ អឹម!

ខ៖ វាថាមិនអោយខ្លាចម៉េច ខ្ញុំថាកុំខ្លាចវាធ្វើតាមសម្រួលទៅ!

ក៖ ចាស! អ៊ំៗទាក់ទងជាមួយនឹងឪពុកម្តាយរបស់អ៊ុំនឹងអ៊ុំប្រាប់ថាគាត់មានឈ្មោះអីគេអ៊ុំ?

ខ៖ ឈ្មោះ ឡេង!

ក៖ អូ...ហើយចុះអ្នកម្តាយវិញ?

ខ៖ លីម គីមហុង!

ក៖ ចាស! គាត់នៅស្រុកអ្នកនៅឯណាដែរអ៊ុំ?

ខ៖ អឺ...ឪពុករបស់នៅនឹងខេត្តព្រៃវែងជាមួយនឹងគាត់នេះ!

ក៖ ចាស! ហើយចុះម្តាយវិញ?

ខ៖ ម្តាយរបស់ខ្ញុំនឹងដូចខ្ញុំបានជំរាបប្រាប់ខាងលើអញ្ចឹងគាត់នៅកំពង់ធំ!

ក៖ ចាស! ហើយឥលូវគាត់នៅតើហីអ៊ុំ?

ខ៖ ស្លាប់អស់រលីង!

កៈ គាត់ស្លាប់នៅក្នុងឆ្នាំណាដែរអ៊ុំ?

ខៈ អឺ...គាត់...គាត់ស្លាប់នៅក្នុងជំនាន់ៗប៉ុលពត!

កៈ អឺម!

ខៈ ឪពុករបស់ខ្ញុំគាត់ស្លាប់នៅក្នុងជំនាន់ប៉ុលពត ៧៧ អូ...៧០ ៧៥ ៧៦ គាត់ស្លាប់ (ឪពុករបស់លោកអ៊ុំស្លាប់នៅក្នុងឆ្នាំ១៩៧៦) ដល់តែម្ដាយរបស់ខ្ញុំគាត់ទើបតែស្លាប់ដែរនឹង!

កៈ អឺម! ចាស!

ខៈ គាត់ស្លាប់ពីរឆ្នាំ បងប្អូនរបស់ខ្ញុំមានប្រាំនាក់!

កៈ ចាស!

ខៈ ប្រុស...ដូចថាប្រុសបីស្លាប់អស់ពីរនាក់នៅសល់តែខ្ញុំមួយនឹងទេ ស្រី...ស្រីពីរនាក់!

កៈ អ៊ុំ...អ៊ុំជាកូនទីប៉ុន្មាន?

ខៈ ខ្ញុំកូនទីពី!

កៈ បងប្អូនរបស់អ៊ុំមានឈ្មោះអីគេខ្លះ?

ខៈ ខ្ញុំ...ខ្ញុំឈ្មោះ ឡេង ពៅ ដល់មួយទៀតឈ្មោះ ឡេង វ៉ា មួយទៀត ឡេង វ៉ាន់ នៅនឹងខាងកំពង់ធំឯណោះគេនឹងគេកាក់កបហើយគេរកស៊ីមានគេ គេមានផ្ទះមានសំប្បែងគេមានលុយផ្ទះនៅផ្ទះធំហើយផ្ទះប្រក់ស័ង្កសីនឹង គេចិត្តបានដែរខ្ញុំទៅលេងអីនឹងអោយលុយខ្ញុំ!

កៈ ចាស!

ខៈ បាទ! ហើយខ្ញុំវិញឃើញក្មួយទៅមិនចង់អធិប្បាយទេ គេកំពុងហូបបាយអញ្ជេកយើងជូនទៅនៅនឹងវត្តហើយគេ ដូចកូនរបស់គាត់អញ្ចឹងគេរាប់រកណាស់ដល់តែយើង...យើងវាមិនសូវជារកអីណាស់យើងនៅនឹងវត្តអញ្ចឹងណាស់ ដល់ហើយខ្ញុំទៅនឹងអីអញ្ចឹងគេមិនសូវរាប់រកខ្ញុំទេ!

ក៖ អឹម!

ខ៖ បើដូចខ្ញុំចិត្តរបស់ខ្ញុំទៅលេងប្អូននឹងទាល់តែយូរបានៗខ្ញុំមកវិញ ទៅប្រាប់ខ្ញុំថាអ៊ីងឯងម៉េចមិនស៊ីបាយខ្ញុំថាអត់ស៊ីទេខ្ញុំហូបរួចហើយ តាមពិតខ្ញុំនៅខ្ញុំមកហូបបាយនៅនឹងវត្ត!

ក៖ អឹម!

ខ៖ ព្រោះខ្ញុំក្រ ហូបបាយក្នុយរបស់ខ្ញុំនឹងគុណណាស់ (ក្រហែម) ដល់ពេលបុណ្យទាននឹងគេ...គេជូនលុយហើយមួយម៉ឺន គាត់អាចារ្យទៅប្រាំ ទៅប្រាំមួយម៉ឺនទៅ ពីរម៉ឺនទៅតាមសទ្ធារបស់គេទេ ជូនណាគេទិញថ្នាំពេទ្យអោយទៅបានរៀងធូរជើងនឹងឯងណាស់!

ក៖ អឹម!

ខ៖ ហើយ!! បានតែថាមីអូនឯង ដល់តែចាស់ហើយកូនរបស់ខ្ញុំនឹងខ្ញុំមិនខឹងគេទេបាទ ខ្ញុំនឹកគិតថាខ្ញុំនៅវត្តមានលុយចាយ បាយមានហូបតែនឹកឃើញកូន ហើយយើងខឹងកូនវាមិនកើត!

ក៖ នឹងហើយ!

ខ៖ យើងជាចាស់ទុំ!

ក៖ ចាស!

ខ៖ ហើយគេគោរពទៀត យើងខឹងរឹតតែមិនកើតទៀតព្រោះសុទ្ធតែកូនស្រីហើយអ្នកខ្លះគេគិតថាអឹម...ម៉េចតានឹងវត្តភ្លើទេហីបានតែរ៉ៃកូនរ៉ៃចៅអញ្ចឹង នែ...បាទ!

ក៖ ត្រូវហើយអ៊ុំ! ត្រូវធ្វើជាគំរូទៅដល់កូនចៅជំនាន់ក្រោយ!

ខ៖ បាទៗ!

កៈ ចុះអ៊ុំទាក់ទងជាមួយនឹងបងប្អូនរបស់អ៊ុំវិញអ៊ុំមិញរាប់បានតែបីនាក់នឹង នៅមានប៉ុន្មាននាក់ទៀតដែរបីនាក់...

ខៈ ស្លាប់អស់មួយប្រុស មួយទៀតលោតទឹក!

កៈ អ៊ឹម!

ខៈ ប្រលងធ្លាក់!

កៈ ប្រលងធ្លាក់ទៅលោតទឹកម៉ង?

ខៈ បាទ!

កៈ អូ...សោកស្ដាយមែនទែន!

ខៈ មនុស្សនឹងមានប្រពន្ធហើយមានដល់ទៅកូនហើយ កូននឹងប៉ុនៗនឹងហែងហើយមានរៀបការហើយតើ!

កៈ អ៊ឹម!

ខៈ មានថៅហើយ នៅនឹងនេះកោះក្របៅយើងនឹង!

កៈ អ៊ឹម!

ខៈ អញ្ចេកទីមួយ ប្អូនរបស់ខ្ញុំវាលក់ខ្ញុំប្រាប់ការពិតម៉ងលក់ដូរហើយថាម៉ែវាអោយដាក់ដាំបាយទៅជាប់មានកូន ណាស់ពោះធំណាស់ ហើយប្រពន្ធពោះធំនឹងនៅ!

កៈ កូនស្រី?

ខៈ បើ...អើវាប្រពន្ធនឹងប្រពន្ធស្រីទេ ប្រាប់ប្រពន្ធនឹងកាលមិនទាន់កូនទេណាស់ប្រាប់ប្រពន្ធពោះធំនឹងថាឯងអើយដាំបាយអោយខ្ញុំ ផងខ្ញុំវាជាប់លក់ឥវ៉ាន់លក់អូ...ប្រឹងណាស់អានោះមែនតើខ្ញុំនិយាយវាមានផ្ទះមានអីមានម៉ូតូ ជិះដល់ដំណើរទៅ វាខឹងដល់មកផ្ទះម៉ែខ្ញុំថាកូន កូនឯងកុំធ្វើបាបប្រពន្ធ ទៅវិញលោតទឹកបណ្ដោយ!

កៈ អឺស!

ខៈ ហើយទៅចាញ់បោកពួគមាក់!

កៈ អឺម!

ខៈ ពួកមាក់នៅនឹងអូឬស្សី អានឹងបាត់ឈឹងអូន!

កៈ អូ…អ៊ុំអើយ!

ខៈ ជិះម៉ូតូអាសង់ទៀត ជិះអាសង់កូរ៉េទៀតមកដល់ទៅវិញបាត់ពួកមាក់ប្អូនរបស់ខ្ញុំក៏ស្លាប់ហើយណាមួយប្រពន្ធរបស់វាថាម៉ែ…ម៉ែឯងមានឃើញប្តីរបស់ខ្ញុំមកនេះទេ? ហ្អាក់?? ហើយម៉េចអញ្ចឹងថាអឺម…មកវែកឆ្នាំមកវែកឆ្នាំបាត់ជ្រាប
បាត់ទាំងម៉ូតូបាត់ទាំងពួកមាក់វាទៀត!

កៈ អឺម!

ខៈ ម្យ៉ាងខ្ញុំអញ្ចេកទៀត ថាដល់តែវាទៅវាថាអឺម…កូនអើយកូនឯងទៅស្អែកឡើងមកទៀតយក…យកម៉ូតូប្រពន្ធវាមកជិះព្រោងទឹកឯណោះ!

កៈ ចាស! អើយអ៊ុំអើយ!

ខៈ ហើយវាដាក់ម៉ូតូហើយនឹងវាមិនសុខចិត្តវាជិះម៉ូតូមកដល់ស្ពានជ្រោយចង្វារ!

កៈ ហើយទៅម៉ូតូនឹងទុកចោលហ៎?

ខៈ បាទ! ម៉ូតូនឹងអត់ដឹងផង!

កៈ អឺម…ហើយអ៊ុំធ្វើម៉េចបានដឹងរឿងនឹងហើយយកសពរបស់គាត់អីទៅណា!

ខៈ អត់ទេប្រពន្ធវាមកផ្ទះរបស់ខ្ញុំ ផ្ទះរបស់ខ្ញុំកាលមុននៅនឹងផ្សារមាន់អាំង នៅនឹងផ្សារមាន់អាំងទួលគោកនឹងដល់ហើយប្រពន្ធរបស់វានឹងនៅនេះនៅកោះក្របីហើយបានដឹងរឿងអញ្ចេកប្រពន្ធរបស់វាមកសួរនឹងម៉ែរបស់ខ្ញុំនឹងណាស់

ថាម៉ែម៉េចឃើញប៉ិរ៉ាមកនឹងអត់ ម៉ែថាអត់ឃើញ! ហ្អាក់?? អញ្ចឹងទៅណាហើយទៅបាត់ទាំងអាពួកមាក់វាទៀត!

ក៖ អ៊ឺម!

ខ៖ បាត់ទាំងម៉ូតូបាត់ទាំងពួកមាក់របស់វាទៀត! ហើយទៅដំណើរនឹងលួច...

ក៖ សោកស្តាយមែនទែនដែលបងប្អូនរបស់អ៊ុំណាស់ដែលថាគាត់មិនសមនឹងគិតខ្លីអញ្ចឹងណាស់...

ខ៖ គិតខ្លីណាស់អានឹងវាគិតខ្លីណាស់ ជឿរតាមពួកមាក់!

ក៖ អ៊ឺម!

ខ៖ ម្យ៉ាងផឹកស៊ី អានោះវាអត់ផឹកស៊ីទេតែវាមិនដឹងម៉េច!

ក៖ ចាស! ហើយអ៊ុំកាលនឹងសាច់របស់បងប្អូនរបស់អ៊ុំកាលពីនៅក្មេងៗឡើយអ៊ុំចងចាំអីគេខ្លះជាមួយពួកគាត់?

ខ៖ ខ្ញុំ...ខ្ញុំតស៊ូដែរចិញ្ចឹមឪពុកម្តាយកាលមុនខ្ញុំលក់នំប៉័ង!

ក៖ អ៊ឺម!

ខ៖ ប្រវត្តិរបស់ខ្ញុំច្រើនណាស់ កាលនឹងរៀនផងលក់ផងចូលរៀនម៉ោងប្រាំពីរ ខ្ញុំថ្នាក់ទីប្រាំបី!

ក៖ អ៊ឺម!

ខ៖ ខ្ញុំរៀនអន់ណាស់ អន់ជាងប្អូនរបស់ខ្ញុំ ប្អូនរបស់ខ្ញុំរៀនបានឌីសប្លូមដល់ពេលនឹងទៅក៏ខ្ញុំលក់ៗស្មើនឹងនិយាយត្រង់ម៉ងវ៉ៃគុយទាវស៊ីឈ្នួលគេណាស់ មួយចានជំនាន់លន់ណុលបានតិចតួចទេមួយចានបានបួនប្រាំរយទៅបានអោយម្តាយទៅអត់ហ៊ានចាយទេយកលុយទិញសៀវភៅទិញប៊ិចទិញអីរៀន អូ...ខ្ញុំរកចិញ្ចឹមម្តាយរបស់ខ្ញុំណាស់

ដល់ពេលនឹងភ្លើងឆេះផ្ទះនៅក្រោយវត្តសង្កែអស់រលីងខ្ញុំបងម៉ែរបស់ខ្ញុំនឹង
ប៉ាខ្ញុំនៅរស់កាលនឹងសុំស្នាក់នៅសុំមានេះគាត់ទៅបាត់ហើយ!

ក៖ ចាសអ៊ុំ!

ខ៖ ដល់ម៉ាខ្ញុំហៅ អឹម...លោកបងទៅស្នាក់នៅនឹងវត្តទៅ!

ក៖ អឹម!

ខ៖ អឹម...ប្រវត្តិរបស់ខ្ញុំច្រើនណាស់កាលនឹង!

ក៖ (សើច)!

ខ៖ ដល់ទៅលោកនឹងលោកអោយមុងអោយកន្ទេលនឹងបីនាក់
ខ្ញុំកាលនឹងបងរបស់ខ្ញុំធ្វើទាហានលន់ណុលទៅបាត់
គាត់អត់ដែលបានចូលផ្ទះទេប្រាក់ខែគាត់ក៏គ្មានអោយនេះផងគាត់មិនអោយម៉ែខ្ញុំផង
គាត់មានស្រីនឹងណាស់នឹងប្រវត្តិរបស់គាត់តែខ្ញុំតស៊ូណាស់ អឹម...បានថាពិបាកណាស់!

ក៖ ចាសអ៊ុំ! ហើយអ៊ុំកាលពីនៅក្មេងៗអ៊ុំចូលចិត្តអីគេខ្លះជាមួយនឹងបងប្អូនរបស់អ៊ុំ?

ខ៖ ខ្ញុំគិតតែពីរៀន!

ក៖ អត់បានលេងអីទេហ៎អ៊ុំ?

ខ៖ អត់មានបានលេងអីទេ រកលុយចិញ្ចឹមម្តាយរបស់ខ្ញុំ!

ក៖ ចាសអ៊ុំ! អ៊ុំរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរអ៊ុំកាលនឹង?

ខ៖ ខ្ញុំ...ទេខ្ញុំរៀនជាងប្អូនរបស់ខ្ញុំទៀតនោះបានត្រឹមថ្នាក់ទីប្រាំ ប្អូនរបស់ខ្ញុំមិនទៅរកស៊ីឯណាខ្ញុំណារ៉ែគុយទាវរៀន
ហើយនៅពេលយប់អញ្ចឹងដើររ៉ែគុយទាវប្រលឹមឡើងទៅយកនំប៉័ងម៉ោងបួន
ពីរនាក់បីនាក់ក៏ពិបាកដែរសុទ្ធតែពួកមាករបស់ខ្ញុំនឹង!

ក៖ ចុះជីវិតរបស់អ៊ុំតាំងពីមុនរហូតដល់ឥលូវនឹងអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំ?

ខៈ ខ្ញុំមិនដែលធ្វើការផង អូ…សំណាង់ខ្ញុំធ្លាប់ធ្វើ!

កៈ ធ្លាប់ធ្វើសំណង់ហ៎អ៊ុំ?

ខៈ បាទ! ខ្ញុំមេជាងការរៀបតដ្ឋការ៉ូនឹងខ្ញុំចេះ!

កៈ អឺម!

ខៈ ហើយប្រាក់របស់ខ្ញុំកាលនឹងមេជាងកាលនឹងគេអោយតិចតួចនឹងដល់ខ្ញុំចេះទៅក៏ចិញ្ចឹមម្ដយរបស់ខ្ញុំទៅក៏ខ្ញុំចេះសម្រេចទៅក៏ឪពុកម៉ានឹងហៅខ្ញុំមកខ្ញុំចេះតែពិបាកចិត្តខ្ញុំនឹងចេះតែដើរដេកហើយដល់ពូរបស់ខ្ញុំនឹងយកខ្ញុំមកពីពេទ្យនឹងមកខ្ញុំឈឺបិះងាប់ស្ដមណាស់កាលនឹងខ្ញុំធ្វើការហើយដុកទ័រៗធំណាស់កាលនឹងហៅខ្ញុំមានឈ្មោះមិនដែលហៅខ្ញុំឈ្មោះឡៃង ពៅទេហៅខ្ញុំថាអាខ្លីៗព្រោះខ្ញុំវាតូចជាងគេ!

កៈ អឺម!

ខៈ (សើច) កាលនឹង(សើច) គេហៅខ្ញុំថាអាខ្លីពូពេទ្យដុកទ័រនឹងមានប្រពន្ធឥលូវបានថៅហើយបានថៅមួយហើយប្រពន្ធរបស់គាត់ស្អាតណាស់ហៅខ្ញុំគាត់ថាម៉េចហើយអាខ្លីហើយឃើញខ្ញុំឥលូវៗនឹងហៅខ្ញុំប្រពន្ធរបស់គាត់នៅចាំខ្ញុំហើយគាត់បបួលខ្ញុំនៅលេងនឹងពេទ្យនឹងដល់ពេលនឹងម៉ែខ្ញុំគាត់អត់នៅអោយខ្ញុំមើលការខុសនៅនឹងលោកតាថាអឺម…បងខ្ញុំថាបងឯងកាត់ចិត្តទៅអញ្ចឹងបងឯងកាត់ចិត្តចុះនៅមើលការខុសត្រូវចុះ គាត់ប្រគល់អោយខ្ញុំមើលការខុសត្រូវទាំងអស់នឹងបាទ ហើយ!! វេទនាណាស់ប្អូនអោយខ្ញុំគិតទៅចង់យំណាស់!

កៈ ឪពុកម្ដាយរបស់អ៊ុំនៅកាលនឹងហើយមកដល់ឥលូវនឹងពួកគាត់ស្លាប់អស់ហើយ!

ខៈ ស្លាប់អស់រលីង!

កៈ ហើយចុះលោកអ៊ុំចាំជីដូនជីតារបស់លោកអ៊ុំដែរឬទេទាំងខាងម្ដាយនឹងខាងឪពុកណាស់?

ខៈ ចាំ អឺ…ម្ដាយរបស់ខ្ញុំ…អឺ…ខាងម្ដាយរបស់ខ្ញុំឈ្មោះយាយ ឡៃហើយតារបស់ខ្ញុំមិនដឹងថាឈ្មោះអីទេខ្ញុំកើតវាមិនទាន់!

កៈ អឺម!

ខ៖ បាទហើយអឺ...ឪពុករបស់ខ្ញុំ....អឺ...ខាងឪពុករបស់ខ្ញុំអត់ស្គាល់តាយាយខ្ញុំអត់ស្គាល់ទេព្រោះខ្ញុំកើតមកមិនទាន់ផង!

ក៖ អឹម...អញ្ចឹងអ៊ុំមានដឹងពីរឿងអីគេខ្លះទាកទងជាមួយនឹងពួកគាត់ដែរអត់?

ខ៖ កាលមុនអត់ដឹងផងព្រោះខ្ញុំនៅតូចៗដែរនឹងខ្ញុំគិតការរៀនសូត្រហើយឃើញគេដើរលេងអញ្ចឹងខ្ញុំគិតថាជីវិតដើរលេងអញ្ចឹងគ្មានប្រយោជន៍ទេ!

ក៖ អឹម!

ខ៖ សុខចិត្តរកចិញ្ចឹមឪពុកម្តាយនឹងបានមានប្រយោជន៍នឹងខ្ញុំគិតខ្លួនឯងតែខ្ញុំអត់ហ៊ាននិយាយទេខ្លាចគេខឹង ខ្លះនៅក្មេងកាលនៅជំនាន់នល់ណុលលេងតែបៀរដើរលេងជុំគ្នាជួនកាលវ៉ៃម្តាយយកលុយឪពុកម្តាយធ្លាក់ពីលើផ្ទះនឹងក៏ឃើញដែរ ម្តាយមិនអោយលុយវ៉ៃម្តាយអានឹងគឺកើតវាថោក...វាថោកយើងម្យ៉ាងយើងមិនរកស៊ីចិញ្ចឹមម្តាយទៅធ្វើបាបម្តាយនឹងហើយផងហុចកម្មមកអោយយើង!

ក៖ អឹម!

ខ៖ ទីមួយទីពីរបើម្តាយមិនអោយលុយជេរម្តាយ អឹម!! មីចុយម្រាយ សម្មាទោសថាមីចុយម្រាយអត់អោយលុយអាញចាយទេអញ្ចឹងទៅទៀតហើយម្តាយអង្គុយយំស្រក់ទឹកភ្នែកអានឹងហើយកម្ម ខ្ញុំមិនដែលទេសួរលោកពូទៅម្តាយខ្ញុំមិនដែលទារលុយពីគាត់មួយរៀលទេមានតែខ្ញុំរកចិញ្ចឹមគាត់វិញ!

ក៖ ចាស!

ខ៖ បាទ!

ក៖ ចុះអាពាហ៍ពិពាហ៍នឹងកាលនឹងអ៊ុំស្រលាញ់គ្នាឬក៏ឪពុកម្តាយជាអ្នករៀបចំអោយអ៊ុំដែរ?

ខ៖ (ក្រហែម) អត់ទេកាលនឹងចេញពីនិយាយអោយត្រង់ចេញពីនឹងទៅអឺ...ខាងប្រពន្ធរបស់ខ្ញុំនឹងខ្ញុំមានប្រព

នូពីរ អញ្ចេកខ្ញុំមិនចង់យកទេដល់ប្រពន្ធរបស់ខ្ញុំស្លាប់ប្រពន្ធរបស់ខ្ញុំស្លាប់នឹងហៅខ្ញុំទៅខ្ញុំទៅនៅជាមួយនឹងម៉ែរបស់ខ្ញុំនៅតាំងគោក គាត់ថាអឺម...អាពៅអើយហែងកំសត់ណាស់អាអឺម...អញ្ចឹងម៉ែឯងកូនធំៗហើយធ្វើការពីមុននៅធ្វើការដល់ឥលូវនឹងឈប់ធ្វើហើយរួចឥលូវលក់ដូរអីចិញ្ចឹមជីវិតប្តីរបស់វានឹងហើយប្តីមិនដែលទេមិនដែលចូលផ្ទះទេ គ្មានចូលផ្ទះទេមីអូនខ្ញុំនិយាយប្រាប់ត្រង់ម៉ង គិតតែដើរមានស្រីសប្បាយម៉ងតែមីប្អូនឯណោះនៅប៉ោយប៉ែតប្រឹងណាស់ ថាប៉ាហើយឥលូវនឹងខ្ញុំប្រឹងណាស់ឥលូវនឹងមានចៅថាថ្ងៃណាមួយយកចៅទៅលេង ចៅប្រុសទៀតអានោះប្រឹងណាស់ថាអឺម...ប្តីរបស់ខ្ញុំប្រឹងណាស់ឥលូវនេះខំទិញទឹកដោះគោឪរបស់វាខំណាស់ ហើយប៉ាឯងម៉េចទៅឈឺជាម៉េចទៅ ខ្ញុំថាជាហើយខ្ញុំថាកូនឯងមិនបាច់ទេកូនខំតែប្រឹងរកទៅអាញមិនអីទេ អឺម...ខ្ញុំនឹកប៉ាឯងណាស់នឹងដឹងកូនរបស់ខ្ញុំមីពៅកាត់មកករកខ្ញុំម៉ងស្រលាញ់ខ្ញុំណាស់ ថាអញ្ចេកអឺម...អត់ពីម្តាយទៅលោកតាមានតែឪពុកទេមីអូនហើយ ឪពុកនឹងហើយធំជាងគេម្តាយស្លាប់បាត់ហើយឥលូវនឹងមានតែឪពុកទេហើយម្យ៉ាងទៀតគោរពគាត់ទៅ យើងមានបាយទឹកនឹងទៅនេះថ្ងៃណាទៅមានជូនគាត់ទៅ លុយកាក់ទៅថាគុណលោកណែនាំមិញនឹង ករុណាររល់ណាស់ថាខ្ញុំ..ខ្ញុំៗមិនមែនទេព្រះតេជគុណៗ ប្រាប់ព្រះតេជគុណអោយដឹងខុសដឹងត្រូវនៅក្នុងវត្តណាស់ ដល់ពេលយកចង្ហាន់មកទៅអោយលោកសរសើរកូនរបស់ខ្ញុំចេះណាស់ មីទីពីរនឹងអត់ចេះឆ្មើងឆ្មៃទេមីអូន កូនស្រីមែនតែមិនចេះល្មោចល្មាចទេ អត់ទេខ្លាចខ្ញុំណាស់!

ក៖ ចាសអ៊ុំ!

ខ៖ ខ្ញុំថាតែមួយម៉ាត់ឈឹង! ខ្ញុំឃើញកូនគេហើយមិនបាច់ទេខ្ញុំទៅលេងប្អូនរបស់ខ្ញុំ...ខ្ញុំឃើញអាខ្លះទៅជក់ម៉ា វ៉ៃប្រពន្ធវ៉ៃបងរបស់ខ្ញុំនៅក្បែរលោកមួយដែរតើ ដល់ហើយប្តីរបស់វាក៏អញ្ចឹងដែរអាក្នុយខ្ញុំនិយាយបរពិត្រ ម៉ូតូអស់មួយម៉ូតូខ្ញុំអោយវាអស់មួយ នឹងពួកមាក់ខ្ញុំវ៉ៃៗទាល់តែទ្រោមហើយនៅទៀត មិនដឹងថាវ៉ៃម៉េចបើវ៉ៃវាៗថែមទៀត!

ក៖ អឺម!

ខ៖ ថាដូចយើងថែមល្បោយចឹងខ្ញុំវ៉ៃវា!

កៈ ចុះអ៊ុំអឺ...កាលនឹងភរិយារបស់អ៊ុំឈ្មោះអីដែរ?

ខៈ បាទ! បើ...កាំង អៀម!

កៈ អឺ....

ខៈ បាទមុននឹង ហើយក្រោយនឹងឈ្មោះមុន!

កៈ ចាស!

ខៈ បាទ!

កៈ អ៊ុំមានកូនប៉ុន្មាននាក់មិញ? អ៊ុំថាកូនជាមួយនឹងប្រពន្ធមុននឹងប៉ុន្មាន?

ខៈ ពីរៗកូនប្រពន្ធក្រោយនឹងអត់មានទេ!

កៈ អញ្ចឹងហ៎?

ខៈ ឥលូវនឹងគេមានប្ដីហើយ បាទ! គេមានប្ដីហើយបានកូនប្រុសមួយហើយម្នាក់ទៀត...

កៈ កូនអ៊ុំនឹង...

ខៈ ប្រពន្ធរបស់ខ្ញុំនឹងក្រោយនឹងគេមានប្ដីហើយ!

កៈ អូ...មានប្ដីមួយទៀតអញ្ចឹង...

ខៈ បាទ!

កៈ គាត់លែងជាមួយនឹងអ៊ុំហ៎?

ខៈ នឹងកាលមុននឹងក៏ខ្ញុំការត្រឹមត្រូវ នេះក៏ការត្រឹមត្រូវនេះរៀបកាលអាពត ដល់នេះខ្ញុំការត្រឹមត្រូវបាទ!

កៈ ប្រពន្ធមុនការត្រឹមត្រូវ?

ខៈ អត់ទេអាពតរៀបអោយ!

កៈ នឹងប្រពន្ធក្រោយណាស់?

ខៈ បាទ រៀបការកាលនឹងការតាមពូ!

កៈ អឺម!

ខៈ ការតាមពូដល់មកដល់ហូបបរនៅរកាកោង បានថាវេទនាណាស់ ហើយការនេះខ្ញុំថាអត់យកទេខ្ញុំអឹម...ម៉ែឯងខ្ញុំស្រលាញ់តែម៉ែឯងម៉ែឯងអោយខ្ញុំយកប្រពន្ធម៉េច?

កៈ អឺម!

ខៈ អឺម...គាត់ថាហែងវាពិបាកវេទនាណាស់! កាលនឹងកូនរបស់ខ្ញុំមីមួយនឹងនៅធ្វើមិនដឹងថាម៉េចៗទេខ្ញុំនៅ
ឯណោះផ្សេងជាមួយនឹងម៉ែរបស់ខ្ញុំទៅ
ដល់តែប្រពន្ធរបស់ខ្ញុំស្លាប់ទៅខ្ញុំមកនៅនឹងវត្តនឹងកូនរបស់ខ្ញុំនៅជំទង់ៗដែរ
មីមួយក្រមុំនឹងដែលថាគេចូលដណ្ដឹងនឹង
ខ្ញុំថាតលូវនឹងអ្នកចូលដណ្ដឹងចូលទៅអឺ...តលូវអញ្ចេកអឺ...តលូវនឹងជន្លងនៅឯកំពត
ឯណោះដល់គេឃើញខ្ញុំនៅនឹងឃើញខ្ញុំនៅនឹងវត្តនឹងគេមិនសូវរាប់រកណាស់!

កៈ អឺម!

ខៈ បាទដល់អញ្ចឹងក៏អញ្ចឹងទៅ ខ្ញុំ...ក្មួយអើយ!

កៈ ចាសអ៊ុំ!

ខៈ ខ្ញុំវេទណាស់!

កៈ ហើយអ៊ុំការស្រលាញ់អឺ...លោកយាយក្រោយណាស់ប្រពន្ធក្រោយរបស់អ៊ុំនឹងកាលនឹងអឺ...មានហៃរជំនូនមានអីដែរទៅទំនៀមទំលាប់...

ខៈ មានៗ កាលមុនជំនាន់នឹងគឺគេជូនគេ១២ម៉ឺនដែរ!

កៈ អូ...

ខ៖ (សើច) ជូនគ្រប់ទាំងអស់នាងខ្ញុំជូនគេគ្រប់ទាំងអស់ខ្ញុំសូមតែប្រាំតុទេ!

ក៖ កាលនឹងអ៊ុំស្រលាញ់គ្នាឬក៏ឪពុកម្តាយជាអ្នករៀបចំអោយ?

ខ៖
កាលនឹងអញ្ចេកខ្ញុំនិយាយនៅនឹងព្រះអង្គគេមកទៅទាកទងជាមួយនឹងម៉ែទៅក៏ម៉ែរបស់ខ្ញុំពេញទៅណាស់ហើយខ្ញុំពោះដល់ហើយគេនៅនឹងក្រមុំ(សើច)
ក្រមុំចាស់ការដល់ហើយខ្ញុំការដល់ហើយកូនខ្ញុំថាបើថាប៉ាឯងមិនយកខ្ញុំកាត់កាលប៉ាចោលដល់ហើយខ្ញុំក៏យកទៅណាស់!

ក៖ (សើច)!

ខ៖ បាទ! ហើយបានម៉ែរបស់ខ្ញុំនឹងគាត់សើច អឺម...បើប៉ាឯងពិបាកប៉ាឯងយកទៅកាលនឹងបានម៉ែខាងស្រីនឹងអត់មានខ្ញុំក៏មេម៉ាយដៃរដល់បងថ្លៃរបស់ខ្ញុំកាចណាស់ខ្ញុំមកនៅនឹងប្អូនអើយ ខ្ញុំទៅសារមងលើខ្ញុំដាច់នឹងដោយសារអីប្រពន្ធរបស់ខ្ញុំកាន់ជើងបងប្អូនគេថ្ងៃមួយបបួលខ្ញុំទៅទាំងយប់អញ្ចេកខ្ញុំនិយាយបរពិតមុខព្រះអង្គបើខ្ញុំនិយាយពន្លើសអោយខ្ញុំងាប់
ថ្ងៃមួយណាស់អ៊ុំទូកទៅវាយមងរួចខ្ញុំអត់ដឹងខ្ញុំអត់ដឹតអីសោះ
ក៏តោះអាពៅហែងទៅដាច់ដោចគ្នាប្រពន្ធខ្ញុំហើយនឹងខ្ញុំនឹងដោយសារអីដោយសារវ៉ៃខ្ញុំអាចុយម្តាយហែងទៅនៅ...ទៅនៅជាមួយម៉ែហែងវិញទៅអាចុយម្តាយខ្ញុំថាគេជេរម្តាយរបស់ខ្ញុំអញ្ចឹងខ្ញុំថាអឺ...បងឯងកុំជេរម៉ែខ្ញុំៗប៉ុន្នឹងហើយបើបងឯងថាម៉េចៗ
ទៅប្រពន្ធរបស់ខ្ញុំថាហែងទៅម្តាយរបស់ហែងវិញទៅ
ខ្ញុំថាឃីហែងដល់នេះទៅតាមបងតាម...បានម៉ែខ្ញុំម៉ែ...ម៉ែក្មេកខ្ញុំថាហែងថាទៅនៅឯណាទៅៗគេហៅប្តឹងគនរបាលប៉ឹបៗខ្ញុំថាតល្ងវខ្ញុំចុះបាន
កាលនឹងឡានតាក់ស៊ីនោះបាទឡានតាក់ស៊ីនឹងខ្ញុំម៉ៅឡានតាក់ស៊ីនឹងមកដល់ភ្នំពេញប្រាំពាន់តើមីអូននឹង ច្បារអំពៅរបស់យើងនឹង!

ក៖ អឺម!

ខ៖ មកដល់ច្បារអំពៅយើងនឹងខ្ញុំជិះមកគេអត់យកលុយទេគេអាណិតខ្ញុំជិះម៉ូតូឌុបមកដល់នឹងមកដល់ពូខ្ញុំថាហ្អាក់?? ម៉េចអញ្ចឹងហែង?

ខ្ញុំថាអឹម...ខ្ញុំលែងគ្នាហើយគាត់អើរអញ្ជឹងនៅវត្តលោកមារបស់ខ្ញុំថាហែងនៅនឹងទៅនៅរហូតខ្ញុំប្រាំពីរឆ្នាំហើយនៅនឹងណាស់ខ្ញុំថាខ្ញុំយកមកខ្ញុំមកអោយចេះធម៌ដែរចេះតិចៗ...

ក៖ អ៊ុំៗចេះប៉ុន្មានភាសាហើយ?

ខ៖ បាទ!

ក៖
អ៊ុំចេះអឺ...អានភាសាចេះភាសាខ្មែរចេះអីអាចអានបានសរសេរអីនឹងណាស់បានល្អដែរឬអត់?

ខ៖ ខ្ញុំអត់សូវចេះផង!

ក៖ ចុះភាសាផ្សេងក្រៅពីភាសាខ្មែរ?

ខ៖ ខ្ញុំឈប់រៀនយូរណាស់ហើយ!

ក៖ ភាសាផ្សេងក្រៅពីភាសាខ្មែរអ៊ុំចេះដែរទេ?

ខ៖ ខ្ញុំចេះអក្សរបានតិចតួចដែរនឹង! ខ្ញុំពូខ្ញុំៗចេះតែយ៉ាំងគិញតែមួយមុខនឹងចេះតែជូនម:ផលតែប៉ុណ្នឹង! តែប៉ុណ្នឹងតែក្មួយអើយ!

ក៖ អក្សរអីអ៊ុំអត់ចេះទេ?

ខ៖ ខ្ញុំឥលូវនឹងវាភ្លេចអស់ហើយវាវិលវល់ក្នុងខួរក្បាលយើងគិតយើងច្រើនពេក!

ក៖ អូ...ចាសអ៊ុំ!

ខ៖ ណាមួយគិតម្តាយស្លាប់ណាមួយប្រពន្ធស្លាប់ហើយណាមួយកូនវាមិនសូវ...វាមិនសូវមកលេងឪហើយអោយឪទៅលេងកូន!

ក៖ ចាសអ៊ុំ!

ខ៖ កូនចិត្តមិនដាច់ទេ ចៅអីខ្ញុំចិត្តមិនដាច់ទេ!

ក៖ អឹម...

ខ៖ ក៏គេចាក់រុកខ្ញុំ មានខ្លះគេចាក់រុកខ្ញុំ ហែងមានលុយហែងអោយថៅធ្វើអីហែងអោយកូនហែងធ្វើអីអោយថៅធ្វើអីថៅហែងដែលមកទេ អញ្ចឹងបានថាខ្ញុំ...ខ្ញុំសើចពូខ្ញុំថាហែងកុំជឿរសម្ដីគេ!

ក៖ អឺម...

ខ៖ ថៅនឹងហើយហែងបន្តិចទៀតហែងដើរលែងរួច
អាញតែតេទៅថៅមកហើយកូនហែងមកហើយកុំទៅជឿរគេ
ជឿរគេដើម្បីអីមីអូនជឿរគេគ្មានបានផងប្រយោជន៍ទេ
កូនយើងណាស់ថៅយើងណាស់មិនអញ្ចឹង?
ចុះបើយើងឈឺយប់ព្រលប់ទៅមានអ្នកណាមានថៅ!

ក៖ ចាស!

ខ៖ នឹងបានកូននឹងហើយបានមក ហើយបើយើងជឿរសម្ដីគេនឹងគឺខកហើយ បាទ!

ក៖ អ៊ុំៗឪពុកម្ដាយរបស់អ៊ុំជីដូនជីតាអីអ៊ុំជនជាតិខ្មែរទាំងអស់ឬក៏...

ខ៖ ខ្មែរ!

ក៖ ខ្មែរសុទ្ធហ៎អ៊ុំ?

ខ៖ បាទ! អូ...ម៉ាររបស់ខ្ញុំចិនម៉ងអូ...យួនម៉ងយួនកាត់ចិន!

ក៖ យួនកាត់ចិន?

ខ៖ អូ...កាចណាស់!

ក៖ (សើច) កាចហ៎អ៊ុំ?

ខ៖ ខ្ញុំមិនរកស៊ីកាំបិតតាំងតោហោះឥលូវហើយ!

ក៖ អូ...(សើច)!

ខ៖ មិនបានទេ!

កៈ អូ...

ខៈ តែបងរបស់ខ្ញុំនេះស្លាប់នេះនិយាយអោយត្រង់ថា បងរបស់ខ្ញុំឈ្មោះឡេងថា ថាហែងទៅលក់នំប៉ុង ខ្ញុំមិនទៅរើរម៉ងកាំបិត គប់ពីក្រោយប៊ុប!

កៈ អឹម...

ខៈ នៅក្រោយវត្តសង្កែរនឹង កាចណាស់ឪមហាកាចហើយសូម្បីតែប្អូនគាត់ធ្វើសង្ឃរាជនេះក៏ខ្លាចគាត់ដែរតែឥលូវគាត់សុគត់ហើយ គាត់ថាសោរកាចណាស់កុំទៅ កូនណាស់ឃើញតែដើរលេងបៀរកាលពីសង្គមនល់នលណាស់ (ស្តាប់មិនបាន ២៧:៣២) គិតតែថាដើរបបួលគេសប្បាយណាស់មួយថ្ងៃៗគិតតែពីដើរលេងស៊ីផឹកម៉ាខ្ញុំអត់ទេ!

កៈ អឹម...

ខៈ គិតពីរកស៊ី កូនណាមិនរកស៊ីអោយដេកក្រោមផ្ទះ!

កៈ (សើច)!

ខៈ ដេកក្រោមផ្ទះព្រោះផ្ទះខ្ញុំធំហើយអត់មានចងមុងហើយទៀត!

កៈ អឹម...ផ្ទះរបស់កាលពីជំនាន់មុនមកដល់ឥលូវនឹងម៉េចមានរូបរាងម៉េចដែរអ៊ុំ?

ខៈ បាទ??

កៈ ផ្ទះរបស់អ៊ុំណាស់កាលពីជំនាន់មុនណាស់?

ខៈ ឆេះអស់ហើយ!

កៈ ឆេះអស់ហើយ?

ខៈ បាទ...

កៈ កាលនឹងម៉េចដែរអ៊ុំឈើធ្វើ...

ខៈ ផ្ទះរបស់ខ្ញុំឈើបីខ្នង!

កៈ បីខ្ទង?

ខៈ ហើយអ្នកព្រៃវែងមកគ្នាអស់ទៅ និយាយប្រវិត្តកាលពីខ្ញុំការប្រពន្ធរបស់ខ្ញុំចិត្តអាក្រក់នឹងប្រពន្ធនេះបរពិតខ្ញុំប្រាប់មីអូនឯង គ្នានៅព្រៃវែងណាស់សុំអង្ករមួយកំប៉ុងមិនអោយទេខ្ញុំអ្នកធ្វើបុណ្យកាលនឹងនៅខ្ញុំមិនទាន់បានមកនៅនឹងវត្តនឹងទេខ្ញុំថា មានអង្ករអោយគេទៅមានអី...អង្ករអោយគេទៅម៉ែក្មេកខ្ញុំណាស់គាត់ក៏នៅដល់ហើយប្រពន្ធរបស់ខ្ញុំ អង្ករតែបន្តិចក៏មិនអោយគេទេ!

កៈ អឺម...

ខៈ គេមកសុំណាស់ បត់ជើងសំពះនៅក្រោមផ្ទះនឹង ចិត្តអាក្រក់ណាស់បានៗខ្ញុំលែងលះគ្នានឹងណាស់!

កៈ អឺម...

ខៈ ដោយសារអីដោយសារតែចិត្តអាក្រក់ ហើយខ្ញុំមកម្តងថាលោកពូខ្ញុំសូមអង្ករមួយកំប៉ុងមកខ្ញុំថាឥលូវទៅដាំបាយនៅក្រោមផ្ទះរបស់ខ្ញុំទៅ ប្រពន្ធរបស់ខ្ញុំដេញទៀត អាចុយម្រាយជេរខ្ញុំម៉ង ចុមហើយម៉េចបានជេរអាញ់អញ្ចឹង ឈប់ណាស់ហើយទៅសិនចាំម៉ែមកសិន ហើយទៅម៉ែខ្ញុំកាន់ជើងកូនដែរថាហែងទុកៗៗហែងក៏ចិត្តធំម្លេះ ហើយបងថ្លៃខ្ញុំជេរខ្ញុំទៅៗហើយខ្ញុំរៀបចំឥវ៉ាន់ភ្លេត!

កៈ អឺម...

ខៈ ហ៊ើយ! ឥស្ញូណាស់ខ្ញុំ!

កៈ ចាសអឺ...

ខៈ បងប្អូនរបស់ខ្ញុំស្លាប់អស់ហើយ!

កៈ អញ្ចឹងអ៊ុំជីវិតរបស់អ៊ុំតាំងពីក្មេងរហូតមកដល់ឥលូវនឹងមានការផ្លាសប្តូរអីគេខ្លះដែរ?

ខៈ មានការផ្លាស់ប្តូរ ឥលូវធូរហើយបានបំរើលោកសង្ឃបានធ្វើបុណ្យដឹងខុសដឹងត្រូវយើងធ្វើអាចារ្យកុំឆេវឆាវ ទីមួយកុំខឹងកុំជឿរពាក្យសម្តីគេ!

កៈ នឹងហើយ!

ខៈ ត្រូវគិតវែងឆ្ងាយយើងចាស់ហើយបាទអញ្ចឹង បាទ!

កៈ អឹម!

ខៈ បាទ!

កៈ ចាសអ៊ុំ! ហើយអឺ...អញ្ចឹងអ៊ុំអឺ...ទាកទងជាមួយនឹងកាលពីមុននឹងអ៊ុំធ្លាប់ធ្វើការងារច្រើនដែរដូចការធ្វើសំណង់ ធ្វើស្រែចំការលក់នំប៉័ងអ៊ុំហ៏?

ខៈ បាទ! យើង...

កៈ អ៊ុំធ្លាប់ធ្វើស្រែដែរឬទេអ៊ុំ?

ខៈ ធ្លាប់ដែរកាលពីខ្ញុំបានប្រពន្ធនៅនឹងខេត្តព្រៃវែងនឹង ខ្ញុំមិនដែលមានធ្វើស្រែទេទើបតែមកដល់ត្រឹមជំនាន់ប៉ុលពតនឹងស្ទូងក៏ចេះដកក៏ចេះដែរ!

កៈ អឹម! កាលពីមុនអ៊ុំចូលចិត្តម្ហូបអីគេដែរពីក្មេងមកដល់ឥលូវនឹង?

ខៈ ខ្ញុំធម្មតា...អើយធម្មតាម៉ែខ្ញុំធ្វើអីខ្ញុំហូបនឹង!

កៈ អត់ប្រកាន់ទេហ៏អ៊ុំ?

ខៈ អត់មានប្រកាន់អីទេ!

កៈ ចុះល្បែងកាលពីអ៊ុំនៅក្មេងៗអ៊ុំចូលចិត្តលេងល្បែងអីគេដែរ?

ខៈ (សើច) អត់ម៉ងព្រោះខ្ញុំអញ្ចេកខ្ញុំនិយាយប្រាប់មីអូនឯងត្រង់តែញៀនល្បែងដឹងតែចេញពីផ្ទះហើយម៉ារបស់ខ្ញុំយួនតែអ្នកណាលេងល្បែងបោះខោអាវអោយចេញពីផ្ទះ!

កៈ អូ...

ខៈ ដឹងតែពីចូលទេគាត់នឹង!

ក៖ (សើច) !

ខ៖ កូនទាល់តែខ្លាចដើម្បីនឹងចេះរកស៊ីទាំងអស់ បងរបស់ខ្ញុំឌីសប្លូម កាលពីរៀនជំនាន់លន់នលនោះ!

ក៖ អឹម!

ខ៖ ខ្ញុំរៀនថ្នាក់ទីប្រាំបី ប្អូនរបស់ខ្ញុំថ្នាក់ទីប្រាំពីរ!

ក៖ អឹម!

ខ៖ ខ្ញុំរៀនចាញ់ប្អូនរបស់ខ្ញុំឆ្ងាញណាស់!

ក៖ ចាស!

ខ៖ ដល់អញ្ចឹងខ្ញុំខំប្រឹងប្រែងរៀនទៅ ស្មើរនឹងទៅវ៉ៃគុយទាវទៅទាល់តែម៉ោងប្រាំបួនបានចូលផ្ទះ ហើយមកលុយមកយកមកអោយម្ដាយទៀតបត់ជើងជូនម្ដាយ!

ក៖ អ៊ុំកាលពីនៅពីក្មេងចូលចិត្តស្ដាប់បទចំរៀងដែរឬទេ?

ខ៖ អូ...អត់ទេគិតតែពីរៀននឹងម៉ង!

ក៖ អូ...

ខ៖ ស្ដាប់បទចំរៀងនឹងអត់មានទេប្អូន!

ក៖ ចុះអ៊ុំមានធំឡើងចង់អី...ដូចថាមានក្ដីប្រាថ្នាចង់ធ្វើអីណាស់ធំឡើង?

ខ៖ អឹម...ខ្ញុំមិនដឹងផងជីវិតរបស់ខ្ញុំ!

ក៖ អឹម! មាន...

ខ៖ ជីវិតរបស់ខ្ញុំមិនដឹងធ្លាក់ទៅដល់ណា!

ក៖ អត់មានក្ដីប្រាថ្នាថាខ្លួននឹងធំឡើងចង់ធ្វើអីទេហ៎?

ខ៖ បាទ! ខ្ញុំចង់ប្រាថ្នាចង់អោយជួបនឹងព្រះសង្ឃ!

ក៖ អូ...

ខ៖ ដើម្បីចង់បានជួបព្រះពុទ្ធព្រះធម៌សង្ឃទេ!

ក៖ ចាស! ចុះ...

ខ៖ តែបើខាងល្បែងអីនឹងគឺថាខ្ញុំមិនចេះលេងជាដាច់ខាត!

ក៖ ចាស! អ៊ុំហើយអឺ...អ្នកណាគេនៅក្នុងសមាជិកនៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងមានដែរឬទេអ៊ុំ?

ខ៖ អត់អឺ...ខាងបងរបស់ខ្ញុំមានបងថ្លៃប្អូនថ្លៃរបស់ខ្ញុំគាត់មានចេះខាងដេញហ្គីតាលេងភ្លេងរាំអីនឹងណាស់ឥលូវនឹងគាត់ស្លាប់បាត់ហើយ នៅស្ទឹងមានជ័យនេះស្ទឹងមានជ័យចំការដូងនេះ!

ក៖ អូ...

ខ៖ បើថ្លៃខ្ញុំធ្វើគ្រូនៅចំការដូងនឹង!

ក៖ អឹម...

ខ៖ (អ៊ុំនិយាយផ្សេងពីការសំភាសន៍)!

ក៖ ចាស! ហើយអ៊ុំអញ្ចឹងសព្វថ្ងៃនឹងអ៊ុំជាពុទ្ធសាសនាជាអាចារ្យនៅក្នុងវត្តដែរន៍អ៊ុំ?មែនទេ?

ខ៖ បាទ!

ក៖ ចុះអ៊ុំហេតុអីបានជាអ៊ុំជឿរទៅលើព្រះពុទ្ធសាសនា?

ខ៖ យើងដូចថាព្រះពុទ្ធសាសនាធំណាស់យើងប្រៀបបាន យើងជាប្រជាជនត្រូវគោរពសាសនាទីមួយ ទីពីរយើងស្តាប់...ស្តាប់អឺ...ព្រះពុទ្ធដែលមានពុទ្ធិការទេសន៍រាល់ថ្ងៃយើងត្រូវស្តាប់បាទ

លោកទេសនានឹងយើងត្រូវមានការស្តាប់ព្រះធម៌ទេសនាទីពីរយើងមិនអាចដើរ...ដើរឆកប្លន់គេដើរលួចគេកុំដើរជេរគេព្រោះយើងជាអាចារ្យវត្ត!

ក៖ ចាស!

ខ៖ បាទ! នឹងហើយព្រោះខ្ញុំជាអាចារ្យ!

ក៖ ចាស! អញ្ចឹងព្រះពុទ្ធសាសនាបានជះឥទ្ធិពលអីគេខ្លះនៅក្នុងជីវិតរបស់អ៊ុំដែរ?

ខ៖ អោយយើងចេះដឹង!

ក៖ ចាស!

ខ៖ ទីមួយកុំអោយដើរពាលលាអាវ៉ាសែ កុំដើរឆក់កុំដើរស្រលាញ់គេ ស្រលាញ់ប្រពន្ធរបស់អានឹងទីមួយ ទីពីរយើងធ្វើអោយត្រឹមត្រូវ!

ក៖ ចាស!

ខ៖ នៅវត្ត!

ក៖ ចាសអ៊ុំ!

ខ៖ បាទ!

ក៖
អ៊ុំហើយអញ្ចឹងសំរាប់បញ្ហាជីវិតរបស់អ៊ុំតាំងពីមុនរហូតមកដល់ឥលូវអ៊ុំធ្លាប់បានជួបនៅបញ្ហាជីវិតអីគេខ្លះដែរ? ច្រើនដែរទេ?

ខ៖ មានដូចដែរខ្ញុំបាននិយាយអញ្ចឹង!

ក៖ ចាស!

ខ៖
ពិបាកតែកាលពីជំនាន់លន់លនហើយនឹងជំនាន់សម្តេចព្រះសីហានុនឹងតែឥលូវនឹងអត់មានទេ!

កៈ ចាស!

ខៈ នៅនឹងវត្តនឹងស្រួល!

កៈ ចាស! មកដល់ជំនាន់ប៉ុលពតអីម៉េចដែរអ៊ុំ? គេជំលៀសអ៊ុំទៅណាដែរ?

ខៈ ជំនាន់អាពតដើរតាមកងចល័ត!

កៈ គេ...អូ...គេជំលៀសអ៊ុំទៅណាដែរ? ដឹង...

ខៈ ជំលៀសទៅព្រៃវែង!

កៈ ជំលៀសទៅទាំងក្រុមគ្រួសារម៉ងហ៎អ៊ុំ?

ខៈ បាទ! ជំលៀសមួយគ្រួសារម៉ង!

កៈ គេប្រើអោយអ៊ុំធ្វើអីគេខ្លះកាលនឹងអ៊ុំ?

ខៈ អឹម...កាប់ដីរែកដី ជំរៅពីរម៉ែត្រកន្លះ!

កៈ (សើច)!

ខៈ រែក...

កៈ អ៊ុំគេធ្វើបាបអត់អញ្ចឹងបើគេប្រើច្រើន?

ខៈ អូ...អត់មានណាគេធ្វើបាបផងកាលនឹងនៅក្មេងៗគ្មានអ្នកណាគេធ្វើបាបអីផង ស្រុកប៉ាខ្ញុំ...

កៈ ម្ហូបអីគេអោយពិសារអីម៉េចដែរ? បបរអី?

ខៈ អឹម...ស្រុកខ្ញុំស្រួលដូចគ្នាតែបើបាននឹងមួយកំប៉ុងបបរទឹករាវ ខ្ញុំមិនដែរទេ!

កៈ បាយរហូត?

ខៈ ប្អូនរបស់ខ្ញុំនឹងអាពៅគេនឹងទៅបាត់ហើយគ្រាន់តែទឹកបបរនឹងវាជះចោលនៅក្រោមគុ!

កៈ អឹម...

ខ៖ ហើយឥលូវនឹងវាទៅបាត់ហើយមានប្រពន្ធមានកូនវាទៅបាត់!

ក៖ កាលនឹងគេអោយបបរទេហ៎មិនមែនទេហ៎អ៊ុំ?

ខ៖ បាយខ្ទះដូចថាប្រធានភូមិមកអញ្ចឹងយូរទៅបបរម្ដងទៅណាស់!

ក៖ ចាស!

ខ៖ ដល់តែឆ្នាំខ្ទះនឹងដាំបាយអោយប្រជាជននឹងបានម៉ែខ្ញុំរួចដែល...ដែលគាត់ស្លាប់បាត់ទៅនឹងស្លាប់ដោយសារឈឺទេមិនមែនអត់បាយទេអឺ...បាននេះប្រធានភូមិនឹងគេគ្រប់ទុកក្នុងឡាំងតែគាត់ចេះតែចាក់សោទៅណាស់បាទចេះតែចាក់សោរទៅដល់ពេលហូបទៅយើងដួសបាយមួយចានម្នាក់នាំគ្នាហូបទៅណាស់!

ក៖ ចាសអ៊ុំ!

ខ៖ សម្លរម្ជូរធម្មតានឹងមីទូច!

ក៖ កាលនឹងអ៊ុំធ្លាប់ឃើញអាពតយកមនុស្សទៅស្លាប់ចោលដែរឬទេអ៊ុំ?

ខ៖ ឃើញ!

ក៖ អឺស!

ខ៖ កាលនឹងវាស្លៀកពាក់ខោខ្មៅអាវខ្មៅ!

ក៖ អឺម!

ខ៖ ហើយទៅសូម្បីតែនឹងក៏វាចាប់ជើងបោកដែរ ព្រោះខ្ញុំដើរកងចល័តបានខ្ញុំដឹងនឹង!

ក៖ អឺម!

ខ៖ ហើយម្យ៉ាងទៀតដូចថា...ដូចថាយើងវាខ្លាចគេយកទៅសម្លាប់ចោលអញ្ចឹងណាស់ទាំងស្រីទាំងប្រុសបើគេយកទៅសម្លាប់ចោលអញ្ចឹងគេអោយជីករណ្ដៅអោយជីករណ្ដៅខ្លួនយើងណាស់

ពីរនាក់អង្គុយនឹងវារ៉ៃនឹងត្បូងចប់ទម្លាក់ចោលម៉ង
កប់ម៉ងវាស្បៀងជើងកង់ឡានវាច្រានទម្លាក់ម៉ង!

ក៖ ចាសអ៊ុំ!

ខ៖ រួចខ្ញុំទាន់ជំនាន់អាពតនឹងតើ!

ក៖ ចាសអ៊ុំ! (អ៊ុំនិយាយជាមួយនឹងអ្នកផ្សេង)!

ខ៖ អញ្ចឹងបានថាពិបាកណាស់!

ក៖ អឹម...ហើយដល់ពេលដាច់មកភ្លាមៗនឹងអ៊ុំមកជួបជុំនឹងគ្រួសារវិញទាំងអសអ៊ុំហ៎? ដាច់ពីជំនាន់អាពតនឹងមកណាស់?

ខ៖ អូ...ខ្ញុំមានផងមកនៅនឹងវត្តនឹងម៉ង!

ក៖ អត់ទាន់ អត់មានបានជួបជុំគ្រួសារអត់មានដំណឹងអី...

ខ៖ បាទៗ! ព្រោះខ្ញុំមកនេះមុនអី...ប្រពន្ធរបស់ខ្ញុំគេមានប្តីអញ្ចឹងទៅណាស់មានទាក់ទងអីទៀតចប់ហើយ!

ក៖ ប្រពន្ធចាស់ហើយនឹងហើយ!

ខ៖ ប្រពន្ធប្អូនខ្ញុំដែរនឹង!

ក៖ អឹម...

ខ៖ ដល់ក្រោយមកបានម៉ែបានវាស្លាប់បាត់ហើយ ដឹងថាខ្ញុំនៅនឹងវត្តនេះវាមកតាមដូចខ្ញុំនិយាយប្រាប់ពីខាងដើមអញ្ចឹង
តាមខ្ញុំទៅថាអោយខ្ញុំទៅដេកឯនឹងភ្នំរៃនៅនឹងមួយយប់ពីរយប់ទៅ!

ក៖ ចាសអ៊ុំ!

ខ៖ បាទ!

កៈ
ជីវិតរបស់អ៊ុំនៅពេលដែលជួបនឹងរឿងដែលពិបាកម្តងៗនឹងអ៊ុំធ្វើយ៉ាងម៉េចដែរដើម្បីនឹងបំបាត់ការលំបាកនឹងណាស់?

ខៈ ខ្ញុំមានទៅធ្វើនៅតែវត្តស្រួលអស់ហើយ ខ្ញុំអត់មានធ្វើអីផង!

កៈ អប់រំផ្លូវចិត្ត ស្តាប់ធមិស្តាប់អីអញ្ចឹងហ៎អ៊ុំ?

ខៈ ធមិដេកស្តាប់លោកទេសម្តងៗខ្ញុំមិនដែលទៅណាទេ!

កៈ អឺម...

ខៈ បាទ!

កៈ
ចុះជីវិតល្អៗវិញលោកអ៊ុំមានដែរអត់ដូចជាបទពិសោធន៍ល្អៗដែលអ៊ុំធ្លាប់ជួបប្រទះហើយធ្វើអោយអ៊ុំសប្បាយចិត្តណាស់?

ខៈ ខ្ញុំមកនៅនឹងវត្តនឹងពិបាកខ្ញុំដែរ បើនៅក្នុងដូចថានៅក្នុងគ្រួសារឃើញកូនប្រសារដើរលេងទៅលេងទៅស៊ីផឹកអីអញ្ចឹងខ្ញុំមិនចូលចិត្ត!

កៈ អឺម...

ខៈ នៅវត្តដូចថានៅជាមួយនឹងកូនអីដល់ហើយគិតពីវាយើងវ៉ៃវាមិនកើតព្រោះយើងជាចាស់ទុំ យើងវ៉ៃវាមិនកើតអានឹងប្តីប្រពន្ធរបស់គេនឹងគេរកស៊ីប្តីប្រពន្ធរបស់គេទៅ!

កៈ ចាស!

ខៈ ទៅឃើញយើងបិទធ្មេចភ្នែកដើរចេញមកណាស់!

កៈ អឺម...

ខៈ បាទ!

ក៖ អឹម...ចាសអ៊ុំ! អញ្ចឹងអ៊ុំតែប៉ុណ្ណឹងទេន៍អ៊ុំន៍?

ខ៖ បាទ!

ក៖ អញ្ចឹងអ៊ុំជាចុងក្រោយអ៊ុំមានជាពាក្យពេជន៍អីដើម្បីនឹងផ្តាំផ្ញើរទៅដល់ជាពិសេសកូនចៅជំនាន់ក្រោយណាស់?

ខ៖ សូមអោយក្មួយៗទាំងអស់កុំអោយដូចខ្ញុំនឹងខ្ញុំ...ខ្ញុំជីវិតរបស់ខ្ញុំក្រណាស់ក្មួយអើយពិបាកណាស់ អរគុណ!

ក៖ ចាសអ៊ុំ! អត់អីទេអរគុណអ៊ុំច្រើនដែលបានធ្វើកិច្ចសំភាសន៍នៅក្នុងថ្ងៃនេះណាស់អ៊ុំអញ្ចឹងអ៊ុំតើអ៊ុំអនុញ្ញាតអោយខ្ញុំធ្វើការយករូបថតរបស់អ៊ុំនឹងហើយនឹងសំលេងរបស់អ៊ុំនៅក្នុងថ្ងៃនេះយកទៅដាក់នៅខាងវេបសាយរបស់ខាងសាលាដែរឬទេ?

ខ៖ អឹម...មានអីខ្ញុំ!

ក៖ ចាសអ៊ុំ! ចាសអញ្ចឹងអរគុណអ៊ុំច្រើនសំរាប់ថ្ងៃនេះដែលបានចំណាយពេល...

ខ៖ ខ្ញុំមិនដែលបានទៅនៅជាមួយនឹងកូនខ្ញុំនៅតែក្នុងវត្តរហូត!

ក៖ ចាសអ៊ុំ! អរគុណច្រើនសំរាប់ថ្ងៃនេះដែលអ៊ុំបានចំណាយពេលវេលាសំរាប់ធ្វើការសំភាសន៍ណាស់អ៊ុំណាស់?

ខ៖ បាទ!

ក៖ ចាស!